# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យព្រះយេស៊ូប្រសូតសម្រាប់បុគ្គលិកការិយាល័យទាំងអស់
# ភ្នំពេញថ្មី ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩
# ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនឆ្ងាយពីជីវិតរបស់យើង

**អត្ថបទទី១៖ វិរបុរស ១៣,២-៧.២៤-២៥ក**

ចាប់ពីពេលនេះទៅ ត្រូវប្រយ័ត្ន កុំពិសាស្រា ឬគ្រឿងស្រវឹងណាឡើយ ហើយក៏មិនត្រូវបរិភោគអ្វីដែលមិនបរិសុទ្ធដែរ ព្រោះនាងនឹងមានផ្ទៃពោះ រួចបង្កើតកូនប្រុសមួយ។ វប ១៣,៤-៥ក

**ដំណឹងល្អ៖ លូកា ១,៥-២៥**

កូននោះនឹងធ្វើឲ្យលោកមានចិត្តសប្បាយរីករាយ ហើយមនុស្សជាច្រើនអបអរសាទរនឹងកំណើតកុមារនោះដែរ។ លក ១,១៤

បងប្អូនជាទីស្រឡាញ់!

ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានកើតជាមនុស្ស និងព្រះបន្ទូលរបស់ព្រះជាម្ចាស់បានយាងមកលើផែនដីនេះដើម្បីបំភ្លឺយើង។ សម្រាប់ការិយាល័យទាំងអស់នៅក្នុងភូមិភាគភ្នំពេញ គ្រប់ការងារដែលយើងធ្វើអាចទៅមុខបានលុះត្រាតែ យើងយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាមូលដ្ឋាននៃទស្សនៈរបស់យើង ជាមូលដ្ឋាននៃសេចក្តីស្រឡាញ់របស់យើង ជាប្រភពនៃកម្លាំងរបស់យើង។ បើយើងភ្លេចព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងអាចមានសកម្មភាពខ្លះៗបាន ប៉ុន្តែវាខុសពីអត្ថទស្សនៈដែលចេញពីគម្ពីរដំណឹងល្អ ដែលព្រះបន្ទូលរបស់ព្រះជាម្ចាស់បានចាប់កំណើតជាមនុស្ស។ ពេលយើងថាព្រះបន្ទូលរបស់ព្រះជាម្ចាស់កើតជាមនុស្ស ណែនាំឲ្យយើងយល់ថាព្រះបន្ទូលរបស់ព្រះជាម្ចាស់មិននៅឆ្ងាយពីជីវិតរបស់យើងប្រចាំថ្ងៃទេ មិនឆ្ងាយពីបញ្ហារបស់យើងប្រចាំថ្ងៃទេ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាព្រះបន្ទូលដែលយើងត្រូវការអនុវត្តនៅក្នុងជីវិតរបស់យើងប្រចាំ។

ថ្ងៃនេះ យើងមានគំនិតច្រើនសម្រាប់ជីវិតរបស់យើងជាប្រចាំ នៅក្នុងអត្ថបទទីមួយ ស្ត្រីដែលមានផ្ទៃពោះគេហាមគាត់មិនឲ្យញ៉ាំស្រានិងគ្រឿងស្រវឹង។ ក្នុងគម្ពីរដែលយើងបានស្តាប់ គេបានសរសេររាប់ពាន់ឆ្នាំមកហើយ មានគំនិតច្រើនដែលណែនាំឲ្យយើងគិតអំពីសុខភាព មានន័យថាព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនឆ្ងាយពីជីវិតរបស់យើងទេ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចូលនៅក្នុងជីវិតរបស់យើងប្រចាំ យើងត្រូវការគិតពិចារណា **តើយើងយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីបំភ្លឺជីវិតរបស់យើងជាគ្រួសារដូចម្តេច? តើយើងយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីបំភ្លឺការងាររបស់យើងក្នុងការិយាល័យទាំងអស់ នៃព្រះសហគមន៍ភូមិភាគភ្នំពេញដូចម្តេច?**

ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ចាប់កំណើតជាមនុស្ស យើងត្រូវការគិតដោយផ្ញើជំនឿរបស់យើង ជីវិតរបស់យើងលើព្រះជាម្ចាស់ដើម្បីទៅមុខ។

យើងត្រូវការយកចិត្តទុកដាក់ នៅក្នុងជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ ជាពិសេសនៅតាមការិយាល័យរបស់យើង ដើម្បីឲ្យយើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងធ្វើតាមសមត្ថភាពយើង ប៉ុន្តែធ្វើអស់ពីសមត្ថភាព ដោយសារព្រះជាម្ចាស់មិនដែលបង្ខំយើងប៉ុន្តែជម្រុញយើងដើម្បីឲ្យយើងទៅមុខ។ នៅក្នុងឆ្នាំថ្មីនេះ ឲ្យយើងនឹកឃើញថាព្រះបន្ទូលរបស់ព្រះជាម្ចាស់ចាប់កំណើតជាមនុស្ស **តើខ្ញុំយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីដឹកនាំការងារក្នុងការិយាល័យរបស់ខ្ញុំដូចម្ដេច?** ឲ្យយើងអានព្រះបន្ទូលមួយនឹងគិត **តើព្រះបន្ទូលនេះអាចបំភ្លឺជីវិតរបស់យើងដូចម្ដេច?** យើងដឹងថា មានតែព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលណែនាំឲ្យយើងទៅជាគ្រីស្តបរិស័ទដ៏ពេញលក្ខណៈ ពោរពេញដោយជំនឿ ពោរពេញដោយសេចក្ដីស្រឡាញ់ និងជាពិសេសពោរពេញដោយសេចក្ដីសង្ឃឹម។

យើងអធិដ្ឋាន ផ្ញើជីវិតរបស់យើងជាអ្នកបម្រើ ជាអ្នកធ្វើការតាមការិយាល័យភូមិភាគភ្នំពេញ ទៅលើព្រះជាម្ចាស់ទៅលើព្រះបន្ទូលរបស់ព្រះអង្គ ដែលចាប់កំណើតជាមនុស្សដើម្បីយើងរួមគ្នាកសាងគ្រួសារមួយដែលចេះសហការគ្នា ដែលចេះស្រឡាញ់គ្នា និងដែលចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ អាម៉ែន៕